ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

# គោលការណ៍ណែនាំសម្រាប់
# ការត្រួតពិនិត្យសហគមន៍កសិកម្ម
# ដោយគណៈកម្មាធិការត្រួតពិនិត្យ

រៀបចំដោយៈ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

ឆ្នាំ២០១៦

បោះពុម្ពលើកទី១

**គោលការណ៍ណែនាំសម្រាប់ការត្រួតពិនិត្យសហគមន៍កសិកម្មដោយគណៈកម្មាធិការត្រួតពិនិត្យ**

បោះពុម្ពផ្សាយ៖ ខែកុម្ភៈ ឆ្នាំ២០១៦

បោះពុម្ពដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (MAFF)

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អសយដ្ឋាន៖ # ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ៖ (០២៣) ៨៨៣ ៤២៧ ទូរសារ៖ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិកា


**តើអ្វីទៅជាការត្រួតពិនិត្យ?** ........ ១

**តើអ្វីទៅជាការត្រួតពិនិត្យសហគមន៍កសិកម្ម?** ........ ១

**តើអ្វីទៅជាគណៈកម្មាធិការត្រួតពិនិត្យ?** ........ ១

**សិទ្ធិ និងភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ** ........ ១

**ជំហានទី ១. ការរៀបចំផែនការសម្រាប់ធ្វើការត្រួតពិនិត្យ** ........ ២

**ជំហានទី ២. ការអនុវត្តផ្ទាល់ក្នុងការត្រួតពិនិត្យ** ........ ៥

**២.១-ការត្រួតពិនិត្យលើការគ្រប់គ្រងទូទៅ** ........ ៥

**២.២-ការត្រួតពិនិត្យការខារហិរញ្ញវត្ថុ** ........ ៧

**២.៣ ការត្រួតពិនិត្យ ការអនុវត្តលើមុខរបរ** ........ ៩

២.៣.១- ត្រួតពិនិត្យលើមុខរបរឥណទាន ........ ៩

២.៣.២-ត្រួតពិនិត្យលើមុខរបរផ្គត់ផ្គង់ (ការទិញទំនិញមកលក់ឱ្យសមាជិក និងអ្នកខាងក្រៅ) ........ ១២

២.៣.៣-ត្រួតពិនិត្យលើមុខរបរទីផ្សារ (ការទិញកសិផលពីសមាជិកលក់ទៅទីផ្សារ) ........ ១២

**ជំហានទី ៣. សភាពការណ៍ដែលបានកត់សម្គាល់ពីការត្រួតពិនិត្យ** ........ ១៣

**ជំហានទី ៤. ការរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិកាត្រួតពិនិត្យ** ........ ១៦

**ជំហានទី ៥. ការរាយការណ៍ជូនមហាសន្និបាត** ........ ១៧

## តើអ្វីទៅជាការត្រួតពិនិត្យ?

ការត្រួតពិនិត្យសំដៅដល់ការត្រួតពិនិត្យដោយផ្តោតលើសកម្មភាពសេដ្ឋកិច្ច បញ្ជីគណនេយ្យ និងសកម្មភាពជំនួញរបស់សហគមន៍កសិកម្ម និងណែនាំដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍។

## តើអ្វីទៅជាការត្រួតពិនិត្យសហគមន៍កសិកម្ម?

យោងតាមមាត្រា ៥០ និងមាត្រា៥២ ក្នុងច្បាប់ស្តីពីសហគមន៍កសិកម្ម ការត្រួតពិនិត្យផ្ទៃក្នុងសហគមន៍កសិកម្ម អាចមានន័យថាគឺជាៈ

- ការត្រួតពិនិត្យមើលថាតើក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ អនុវត្តការងារបានត្រឹមត្រូវឬទេ ដោយប្រតិបត្តិតាមច្បាប់និងបទបញ្ជាដែលពាក់ព័ន្ធទាំងអស់ប្រកបដោយវិចារណញ្ញាណ
- ធានាបាននូវភាពទទួលខុសត្រូវចំពោះសមាជិកសហគមន៍កសិកម្ម ដោយធ្វើការត្រួតពិនិត្យបញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌ(បញ្ជីទ្រព្យសម្បត្តិ) និងតារាងតុល្យការជាដើម
- ផ្តល់ដំណឹងទៅក្រុមប្រឹក្សាភិបាលវិញនូវអ្វីដែលបានកត់សំគាល់ និងរៀបចំចងក្រងជារបាយការណ៍ប្រចាំឆ្នាំដើម្បីដាក់ជូនមហាសន្និបាត។

## តើអ្វីទៅជាគណៈកម្មាធិការត្រួតពិនិត្យ?

យោងតាមមាត្រា ៥០ នៃច្បាប់ស្តីពីសហគមន៍កសិកម្ម គណៈកម្មាធិការត្រួតពិនិត្យ ជាអង្គការត្រួតពិនិត្យអចិន្ត្រៃយ៍ផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ដែលមានភារកិច្ចត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សាភិបាលនិងនាយកប្រតិបត្តិដើម្បីរក្សាគណនេយ្យភាពដល់សមាជិករបស់សហគមន៍កសិកម្ម។ គណៈកម្មាធិការត្រួតពិនិត្យត្រូវបោះឆ្នោតជ្រើសរើសដោយមហាសន្និបាត។ ប្រធានគណៈកម្មាធិការត្រួតពិនិត្យត្រូវបោះឆ្នោតជ្រើសរើសក្នុងចំណោមសមាជិករបស់ខ្លួន។

## សិទ្ធិ និងភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ

យោងតាមមាត្រា៥១ និងមាត្រា ៥២ នៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងលក្ខន្តិកៈគំរូសម្រាប់សហគមន៍កសិកម្ម គណៈកម្មាធិការត្រួតពិនិត្យមានសិទ្ធិនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបណ្តាសេចក្តីសម្រេចរបស់មហាសន្និបាតរបស់សហគមន៍កសិកម្ម
- ត្រួតពិនិត្យលើសកម្មភាពរបស់ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ ដើម្បីធានារាល់កិច្ចការទាំងឡាយរបស់សហគមន៍កសិកម្ម ឱ្យមានសង្គតិភាពជាមួយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ច្បាប់ស្តីពីសហគមន៍កសិកម្ម និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- ស្នើសុំឱ្យអ្នកពាក់ព័ន្ធក្នុងសហគមន៍កសិកម្ម ផ្តល់នូវឯកសារចាំបាច់ និងថតចម្លងឯកសារ ជាកម្មវត្ថុសម្រាប់ត្រួតពិនិត្យ
- ធ្វើការត្រួតពិនិត្យ ឬបញ្ជាឱ្យត្រួតពិនិត្យបញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ តារាងតុល្យការ និងឯកសារហិរញ្ញវត្ថុផ្សេងទៀត ដែលកត់ត្រានូវស្ថានភាពមុខជំនួញនិងប្រតិបត្តិការហិរញ្ញវត្ថុរបស់សហគមន៍កសិកម្ម។

- ត្រូវរៀបចំកិច្ចប្រជុំការងាររបស់ខ្លួនយោងតាមការចាំបាច់
- ត្រូវជូនព័ត៌មានស្តីពីសភាពការណ៍ ដែលខ្លួនបានត្រួតពិនិត្យ ទៅក្រុមប្រឹក្សាភិបាល ហើយរៀបរាប់អំពីបញ្ហានេះ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ជូនមហាសន្និបាត
- ទទួលពាក្យបណ្តឹង ការតវ៉ាពាក់ព័ន្ធនឹងប្រតិបត្តិការមុខជំនួញរបស់សហគមន៍កសិកម្មដើម្បីរកដំណោះស្រាយ ឬលើកសំណើជូនអង្គភាពមានសមត្ថកិច្ចដោះស្រាយលើបណ្តឹង ឬការតវ៉ានោះស្របតាមលក្ខន្តិកៈ និងច្បាប់ជាធរមាន
- ស្នើឱ្យប្រធានក្រុមប្រឹក្សាភិបាលកោះប្រជុំ ឬបើកមហាសន្និបាតវិសាមញ្ញ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ជាក់លាក់ណាមួយរបស់សហគមន៍កសិកម្មខ្លួន
- រៀបចំរបៀបវារៈ និងកោះអញ្ជើញមហាសន្និបាតវិសាមញ្ញ នៅពេលកើតមានបញ្ហាចាំបាច់នៅក្នុងសហគមន៍កសិកម្ម ដើម្បីប្រជុំដោះស្រាយ តាមករណីដូចខាងក្រោម៖
    - កើតមានអំពើល្មើសណាមួយចំពោះច្បាប់ស្តីពីសហគមន៍កសិកម្ម លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ឬសេចក្តីសម្រេចរបស់មហាសន្និបាត ដែលក្នុងនោះក្រុមប្រឹក្សាភិបាលខកខានមិនបានចាត់វិធានការចំពោះករណីល្មើសនោះ
    - ករណីក្រុមប្រឹក្សាភិបាលបានខកខានកោះអញ្ជើញមហាសន្និបាតវិសាមញ្ញដើម្បីដោះស្រាយបញ្ហាដោយអនុលោមតាមលក្ខន្តិកៈនេះ
- ធ្វើរបាយការណ៍ត្រួតពិនិត្យស្តីពីប្រតិបត្តិការមុខជំនួញ និងការគ្រប់គ្រងទូទៅរបស់សហគមន៍កសិកម្ម និងរាយការណ៍ជូនមហាសន្និបាត នៅរាល់ដំណាច់ឆ្នាំសារពើពន្ធ

## ជំហានទី ១. ការរៀបចំផែនការសម្រាប់ធ្វើការត្រួតពិនិត្យ

- ក្រោយពីបិទបញ្ជីគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥(ឆ្នាំមុន) ដែលជាថ្ងៃចុងក្រោយនៃការិយបរិច្ឆេទឆ្នាំ២០១៥(ឆ្នាំមុន) ក្រុមប្រឹក្សាភិបាលចាប់ផ្តើមរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៥(ឆ្នាំមុន) និងធ្វើមហាសន្និបាតប្រចាំឆ្នាំចុងក្រោយបំផុតនៅត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៦ (ឆ្នាំថ្មី) ។
- គណៈកម្មាធិការត្រួតពិនិត្យ ត្រូវពិភាក្សាជាមួយក្រុមប្រឹក្សាភិបាល និងសម្រេចពីកាលបរិច្ឆេទច្បាស់លាស់ដើម្បីធ្វើការត្រួតពិនិត្យសម្រាប់ការត្រួតពិនិត្យដំណាច់ឆ្នាំ "end-of-term (fiscal year)" ។ ធម្មតាកាលបរិច្ឆេទសម្រាប់ការត្រួតពិនិត្យ ត្រូវកំណត់ក្រោយពីក្រុមប្រឹក្សាភិបាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុចប់រួចរាល់ ។ ត្រូវពិចារណាពីរយៈពេលដែលគណៈកម្មាធិការត្រួតពិនិត្យ ត្រូវចំណាយសម្រាប់រៀបចំរបាយការណ៍ត្រួតពិនិត្យដំណាច់ឆ្នាំ លៃលកធ្វើយ៉ាងណាឱ្យចប់កិច្ចការ របស់គណកម្មាធិការត្រួតពិនិត្យយ៉ាងហោចត្រូវរួចរាល់ នៅមុនរៀបចំមហាសន្និបាតប្រចាំឆ្នាំមួយថ្ងៃ ។
- គណៈកម្មាធិការត្រួតពិនិត្យត្រូវធ្វើការត្រួតពិនិត្យ ក្នុងមួយឆ្នាំម្តងជាចាំបាច់ ។
- "ការត្រួតពិនិត្យដំណាច់ឆ្នាំសារពើពន្ធ End-of-term monitoring" គឺត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សាភិបាលនិងនាយកប្រតិបត្តិរយៈពេលពេញមួយឆ្នាំ បន្ទាប់ពីថ្ងៃចុងក្រោយនៃការិយបរិច្ឆេទមុខរបរ
- ក្រោយពីសម្រេចអំពីកាលបរិច្ឆេទសម្រាប់"ការត្រួតពិនិត្យដំណាច់ឆ្នាំ End-of-term monitoring" គណកម្មាធិការត្រួតពិនិត្យត្រូវបង្កើតកម្មវិធីសម្រាប់ធ្វើការត្រួតពិនិត្យ ។

– ត្រូវកំណត់កម្មវិធីត្រួតពិនិត្យឱ្យបានច្បាស់លាស់

*នៅពេលដែលគណៈកម្មាធិការត្រួតពិនិត្យរៀបចំកម្មវិធីត្រួតពិនិត្យ ពួកគេត្រូវពិចារណានូវចំណុចដូចខាងក្រោម៖*

*(១) តើការត្រួតពិនិត្យគួរប្រព្រឹត្តទៅនៅពេលណា និងប្រើរយៈពេលប៉ុន្មានថ្ងៃ?*

- មិនឱ្យហួសឆ្ងាយពីថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំបានរៀបចំរួចរាល់ពេកទេ
- ការត្រួតពិនិត្យ ត្រូវធ្វើមុនពេលមហាសន្និបាតប្រចាំឆ្នាំ( ចន្លោះខែមករា និង មិនារៀងរាល់ឆ្នាំ)
- គួរកំណត់ធ្វើការត្រួតពិនិត្យរយៈពេលពីរទៅបីថ្ងៃ (អាស្រ័យទៅនឹងទំហំសហគមន៍កសិកម្ម)

* <u>ដែនកំណត់នៃការត្រួតពិនិត្យ</u>

ជាគោលការណ៍គណៈកម្មាធិការត្រួតពិនិត្យ ត្រូវត្រួតពិនិត្យភាពត្រឹមត្រូវនៃការកត់ត្រាគណនីតាមរយៈឯកសារភស្តុតាង និងត្រូវពិនិត្យគ្រប់សកម្មភាពនិងឯកសារហិរញ្ញវត្ថុទាំងអស់ ។ ដោយសារតែការធ្វើបែបនេះចំណាយពេលច្រើន ដូចនេះគួរត្រួតពិនិត្យដោយផ្តោតតែចំពោះចំណុចគោលៗ ដូចជាសកម្មភាពសំខាន់ៗនិងទាក់ទងនឹងប្រាក់កម្ចីដែលមានចំនួនច្រើន និងសេចក្តីសម្រេចដែលមិនអនុម័ត ឬមិនអនុម័តដោយក្រុមប្រឹក្សាភិបាលឬមហាសន្និបាត ។ ការត្រួតពិនិត្យតិចឬច្រើន អាស្រ័យនឹងទំហំមុខរបររបស់សហគមន៍កសិកម្ម ។

មុននឹងប្រតិបត្តិការការត្រួតពិនិត្យគណៈកម្មាធិការត្រួតពិនិត្យត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលអំពីអ្វីដែលពួកគាត់ត្រូវសួរក្នុងថ្ងៃត្រួតពិនិត្យ និងត្រូវសុំឱ្យសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ចូលរួមក្នុងពេលត្រួតពិនិត្យដែរ។ ទន្ទឹមនឹងនេះដែរ ក្រុមប្រឹក្សាភិបាលត្រូវរៀបចំ ឯកសារភស្តុតាងទាំងអស់យកមកត្រៀមបង្ហាញក្នុងថ្ងៃត្រួតពិនិត្យ។

ឧទាហរណ៍៖ ខាងក្រោមនេះ គឺជាកម្មវិធីត្រួតពិនិត្យ៖

| **ថ្ងៃខែឆ្នាំ និងម៉ោង** | **សកម្មភាពរបស់គណៈកម្មាធិការត្រួតពិនិត្យ** |
|---|---|
| **ថ្ងៃទី១** (**ថ្ងៃទី**............ **ខែ**.............. **ឆ្នាំ** 20.......) | |
| ព្រឹក<br>8:00-9:30 | *២.១ ត្រួតពិនិត្យលើការគ្រប់គ្រងទូទៅ*<br>– ត្រួតពិនិត្យរចនាសម្ព័ន្ធ និងការគ្រប់គ្រង |
| 9:30-9:45 | *សម្រាក* |
| 9:45-11:30 | – ត្រួតពិនិត្យបញ្ជីទ្រព្យសម្បត្តិរយៈពេលវែងរបស់សហគមន៍(បញ្ជីទ្រព្យសម្បត្តិ) |
| ល្ងាច<br>2:00-3:30 | *២.២ ត្រួតពិនិត្យលើការងារហិរញ្ញវត្ថុ*<br>- ពិនិត្យសាច់ប្រាក់ ប្រាក់ចំណេញមិនទាន់បែងចែក ប្រាក់ផ្ញើធនាគារ |
| 3:30-3:45 | *សម្រាក* |
| 3:45-5:00 | *២.៣ ត្រួតពិនិត្យលើការប្រកបមុខរបរ*<br>○ មុខរបរឥណទាន<br>– ប្រាក់ឱ្យសមាជិកនិងមិនមែនសមាជិកខ្ចី |
| **ថ្ងៃទី២** (**ថ្ងៃទី**............ **ខែ**.............. **ឆ្នាំ** 20.......) | |
| ព្រឹក<br>8:00-11:30 | - ប្រាក់បញ្ញើសន្សំពីសមាជិកនិងមិនមែនសមាជិក<br>○ ពិនិត្យមុខរបរផ្គត់ផ្គង់ (តម្លៃ ប្រាក់ចំណេញ និងបញ្ជីសារពើភ័ណ្ឌ)<br>○ ពិនិត្យមុខរបរទីផ្សារ (តម្លៃ ប្រាក់ចំណេញ និងបញ្ជីសារពើភ័ណ្ឌ)<br>○ ពិនិត្យមុខរបរផ្សេងទៀតបើមាន |

តារាង៖ ជំហានអំពីការត្រួតពិនិត្យដំណាច់ឆ្នាំ "end-of-term monitoring" ដោយគណៈកម្មាធិការត្រួតពិនិត្យ

ការត្រួតពិនិត្យត្រូវបានធ្វើនៅចន្លោះខែមករានិងចុងខែមីនារៀងរាល់ឆ្នាំ



## ជំហានទី ២. ការអនុវត្តផ្ទាល់ក្នុងការត្រួតពិនិត្យ

គណៈកម្មាធិការត្រួតពិនិត្យ ត្រូវធ្វើការត្រួតពិនិត្យដោយយោងតាមតារាងកម្មវិធីដែលបានកំណត់ ។ សមាជិកគណៈកម្មាធិការត្រួតពិនិត្យទាំងអស់ ត្រូវចូលរួមក្នុងការត្រួតពិនិត្យ ។

ខាងក្រោមនេះ គឺជាតារាងត្រួតពិនិត្យដែលមានធាតុសំខាន់ៗដូចជាចំណុចត្រួតពិនិត្យ និងរបៀបត្រួតពិនិត្យ ជាមួយនឹងចម្លើយ "មាន" ឬ "មិនមាន" ។ បើសិនជាមានអ្វីត្រូវបន្ថែមទៅលើចម្លើយ គណៈកម្មាធិការត្រួតពិនិត្យ ត្រូវធ្វើ "កំណត់ចំណាំ" នៅក្នុងតារាងកំណត់ចំណាំ ។

ប្រធានបទដែលត្រូវត្រួតពិនិត្យ មានបីដូចជា៖

- ការត្រួតពិនិត្យលើការគ្រប់គ្រងទូទៅ (ពិនិត្យរចនាសម្ព័ន្ធនិងការគ្រប់គ្រង និងបញ្ជីទ្រព្យសម្បត្តិរយៈពេលវែងរបស់សហគមន៍)
- ការត្រួតពិនិត្យការងារហិរញ្ញវត្ថុ (សាច់ប្រាក់ ការបែងចែកប្រាក់ចំណេញ និងប្រាក់បញ្ញើធនាគារ)
- ការត្រួតពិនិត្យលើការអនុវត្តមុខរបរ គឺផ្តោតសំខាន់លើមុខរបរឥណទានដែលរួមមានប្រាក់ឱ្យសមាជិក និងមិនមែនសមាជិកខ្ចី និងប្រាក់បញ្ញើសន្សំពីសមាជិកនិងមិនមែនសមាជិក ហើយបើសហគមន៍កសិកម្មប្រកបមុខរបរផ្សេងទៀត នោះគណៈកម្មាធិការត្រួតពិនិត្យក៏ត្រូវធ្វើការត្រួតពិនិត្យផងដែរ ។

### ២.១-ការត្រួតពិនិត្យលើការគ្រប់គ្រងទូទៅ

| | ត្រួតពិនិត្យមើល | របៀបត្រួតពិនិត្យ | មាន | មិនមាន | កំណត់ចំណាំ |
|---|---|---|---|---|---|
| ***រចនាសម្ព័ន្ធ និងការគ្រប់គ្រង*** | | | | | |
| ១ | តើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ មានរក្សាទុកនៅក្នុងការិយាល័យរបស់សហគមន៍កសិកម្មដែរឬទេ? | សួរប្រធានក្រុមប្រឹក្សាភិបាល និងសុំឱ្យសមាជិកក្រុមប្រឹក្សាភិបាលបង្ហាញនូវលក្ខន្តិកៈគំរូ | | | |
| ២ | បើសហគមន៍កសិកម្មកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងទូទៅ តើកំណែប្រែទាំងនេះបានអនុម័តដោយមហាសន្និបាត និងបញ្ជូនទៅមន្ទីរកសិកម្មខេត្តដែរឬទេ? | -សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញនូវលក្ខន្តិកៈគំរូដែលបានកែប្រែ<br>-ទូរស័ព្ទទៅមន្ទីរកសិកម្មខេត្តបញ្ជាក់តើលក្ខន្តិកៈគំរូដែលបានកែប្រែត្រឹមត្រូវឬអត់<br>-ពិនិត្យឯកសារភស្តុតាងហត្ថលេខាប្រគល់/ទទួលរបាយការណ៍ពីមន្ទីរកសិកម្មខេត្ត | | | |
| ៣ | តើក្រុមប្រឹក្សាភិបាលបានជ្រើសរើសលេខាធិការ និងហិរញ្ញិកក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលឬទេ? | សួរក្រុមប្រឹក្សាភិបាល និងឱ្យអ្នកទាំងនោះ បង្ហាញខ្លួន<br>-ពិនិត្យកំណត់ហេតុប្រជុំជ្រើសរើសរបស់ក្រុមប្រឹក្សាភិបាល | | | |
| ៤ | តើសហគមន៍កសិកម្មមានបញ្ជីសមាជិកសហគមន៍ដែលមាន ឈ្មោះ អាសយដ្ឋានសហគមន៍ ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំ | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញនូវឯកសារដែលមានឈ្មោះ អាសយដ្ឋានសហគមន៍ ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើតនិងអាសយដ្ឋានសមាជិកនិង | | | |

| | | | | | |
|---|---|---|---|---|---|
| | កំណើតនិងអាស័យដ្ឋានសមាជិកនិងថ្ងៃខែចូលជាសមាជិកឬទេ? | ថ្ងៃខែចូលជាសមាជិក តើមានគ្រប់ឬទេ | | | |
| ៥ | តើសហគមន៍កសិកម្មមានបញ្ជីភាគហ៊ុនរបស់សមាជិកដែលមានឈ្មោះនិងអាស័យដ្ឋានសហគមន៍ ឈ្មោះនិងអាស័យដ្ឋានអ្នកមានភាគហ៊ុន តម្លៃភាគហ៊ុន និងចំនួនភាគហ៊ុន និងបានបង់រួចហើយដែរឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញនូវឯកសារដែលមានឈ្មោះនិងអាស័យដ្ឋានសហគមន៍ ឈ្មោះនិងអាស័យដ្ឋានអ្នកមានភាគហ៊ុន តម្លៃភាគហ៊ុន និងចំនួនភាគហ៊ុន និងបានបង់រួចហើយដែរឬអត់ | | | |
| ៦ | តើក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មមានប្រជុំប្រចាំខែដែរឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញកំណត់ហេតុប្រជុំប្រចាំខែ | | | |
| ៧ | តើក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មមាន ប្រជុំមហាសន្និបាតមួយឆ្នាំម្តងដែរឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញកំណត់ហេតុប្រជុំមហាសន្និបាត | | | |
| ៨ | តើសហគមន៍កសិកម្មមានរក្សាទុកកំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល កំណត់ហេតុមហាសន្និបាតប្រចាំឆ្នាំ របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍គ្រប់ប្រភេទផ្សេងទៀតឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញកំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល កំណត់ហេតុមហាសន្និបាត របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍គ្រប់ប្រភេទផ្សេងទៀតឬទេ? | | | |
| ៩ | តើផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការថវិកាសម្រាប់ការិយបរិច្ឆេទខាងមុខរបស់សហគមន៍កសិកម្ម បានអនុម័តដោយមហាសន្និបាតដែរឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញកំណត់ហេតុប្រជុំមហាសន្និបាតថាតើផែនការសកម្មភាពប្រចាំឆ្នាំនិងផែនការថវិកាសម្រាប់ការិយបរិច្ឆេទខាងមុខរបស់សហគមន៍បានអនុម័តរួច | | | |
| ១០ | តើរបាយការណ៍ការធ្វើជំនួញ តារាងតុល្យការ របាយការណ៍ចំណេញឬខាត និងតារាងបែងចែកប្រាក់ចំណេញ បានអនុម័តដោយមហាសន្និបាតដែរឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញកំណត់ហេតុប្រជុំមហាសន្និបាតថាតើរបាយការណ៍ការធ្វើជំនួញ តារាងតុល្យការ របាយការណ៍ចំណេញឬខាត និងតារាងបែងចែកប្រាក់ចំណេញ បានអនុម័តដោយមហាសន្និបាត | | | |
| ១១ | តើជំនួញរបស់សហគមន៍មានខាតដែរឬទេ?បើខាតតើមុខរបរអ្វី? | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញរបាយការណ៍ចំណេញឬខាត និងពិនិត្យមើលក្នុងមុខរបរនិមួយៗ | | | |
| ១២ | តើសហគមន៍កសិកម្មមានបញ្ជូនរបាយការណ៍ប្រចាំឆ្នាំទៅមន្ទីរកសិកម្មខេត្តដែរឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលតើគាត់បានបញ្ជូនទៅឬនៅ អាចទូរស័ព្ទសួរទៅមន្ទីរកសិកម្មខេត្ត ឬពិនិត្យឯកសារភស្តុតាងហត្ថលេខាប្រគល់/ទទួលរបាយការណ៍ពីមន្ទីរកសិកម្មខេត្ត | | | |

| | | | | | |
|---|---|---|---|---|---|
| ***បញ្ជីទ្រព្យសម្បត្តិរយៈពេលវែង*** | | | | | |
| ១ | តើសហគមន៍កសិកម្មមានបញ្ជីទ្រព្យសកម្មរយៈពេលវែងដែរឬទេ? | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញបញ្ជីទ្រព្យសកម្មរយៈពេលវែង | | | |
| ២ | តើទ្រព្យសកម្មរយៈពេលវែងសហគមន៍កសិកម្ម ដែលមានក្នុងបញ្ជីទ្រព្យ មានប័ណ្ណកម្មសិទ្ធ/ប័ណ្ណផ្ទេរកម្មសិទ្ធលិខិតបញ្ជាក់ ឬវិក័យប័ត្រឬទេ?តើឈ្មោះម្ចាស់កម្មសិទ្ធិជារបស់សហគមន៍កសិកម្មដែរឬទេ? | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញ ប័ណ្ណកម្មសិទ្ធ/ប័ណ្ណផ្ទេរកម្មសិទ្ធលិខិតបញ្ជាក់ឬវិក័យប័ត្រ និងឈ្មោះ ម្ចាស់កម្មសិទ្ធិជារបស់សហគមន៍ឬទេ<br>បើមិនមែនគណៈកម្មាធិការត្រួតពិនិត្យត្រូវស្នើឱ្យក្រុមប្រឹក្សាភិបាលសុំឱ្យអាជ្ញាធរមូលដ្ឋានចេញលិខិតបញ្ជាក់ឱ្យទ្រព្យនោះជាកម្មសិទ្ធរបស់សហគមន៍ | | | |
| ៣ | តើចំណាយសម្រាប់ទិញទ្រព្យសកម្មរយៈពេលវែងរបស់សហគមន៍កសិកម្មមានភាពត្រឹមត្រូវនិងសមហេតុផលដែរឬទេ? | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញ វិក័យប័ត្រចំណាយទិញទ្រព្យនោះជ្រើសរើសវិក័យបត្រ២ ៣ សន្លឹក ពិនិត្យមើលប្រៀបធៀបតម្លៃជាក់ស្តែងនៅទីផ្សារថាតើតម្លៃដែលបានទិញសមហេតុផលឬទេ | | | |
| ៤ | តើតម្លៃសរុបទ្រព្យសកម្មរយៈពេលវែងក្នុងសៀវភៅទ្រព្យសហគមន៍ដូចគ្នានឹងចំនួនទឹកប្រាក់ក្នុងតារាងតុល្យការឬទេ? | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញ តម្លៃសរុបទ្រព្យសកម្មរយៈពេលវែងនិងតារាងតុល្យការនិងផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់ | | | |

## ២.២-ការត្រួតពិនិត្យការងារហិរញ្ញវត្ថុ

ជាការត្រួតពិនិត្យរកភាពត្រឹមត្រូវ នៃការកត់ត្រាគណនីតាមរយៈឯកកសារភស្តុតាង ។

| | ត្រួតពិនិត្យមើល | របៀបត្រួតពិនិត្យ | មាន | មិនមាន | កំណត់ចំណាំ |
|---|---|---|---|---|---|
| ***សាច់ប្រាក់*** | | | | | |
| ១ | តើចំនួនសាច់ប្រាក់នៅដៃនៅថ្ងៃត្រួតពិនិត្យដូចគ្នានឹងចំនួនបានកត់ត្រាក្នុងសៀវភៅសាច់ប្រាក់ឬទេ? | -ស្នើឱ្យក្រុមប្រឹក្សាភិបាលបង្ហាញសៀវភៅសមតុល្យសាច់ប្រាក់ឆ្នាំមុន(ត្រឹមថ្ងៃទី៣១ ខែធ្នូ) និងសៀវភៅសាច់ប្រាក់បច្ចុប្បន្ន និងរាប់សាច់ប្រាក់នៅដៃក្នុងថ្ងៃត្រួតពិនិត្យ<br>-ពិនិត្យមើលសាច់ប្រាក់នៅដៃក្នុងថ្ងៃត្រួតពិនិត្យ (ឧ.130$)<br>-ពិនិត្យមើលចំនួនសាច់ប្រាក់នៅសល់ពីឆ្នាំមុន(ឧ.100$) | | | |

| | | | | | |
|---|---|---|---|---|---|
| | | -ពិនិត្យមើលសមតុល្យសាច់ប្រាក់ពីសកម្មភាពក្នុងឆ្នាំថ្មីចាប់ពីថ្ងៃទី១ ខែមករាដល់ថ្ងៃត្រួតពិនិត្យ (ឧ.សាច់ប្រាក់ចូលចំនួន40$ សាច់ប្រាក់ចេញអស់ 10$ គឺ:<br>**= 40$ ដក10$ នៅសល់ 30$)**<br>-យកចំនួនសាច់ប្រាក់ដែលនៅសល់ពីឆ្នាំមុន(100$) **បូក** ចំនួនសមតុល្យសាច់ប្រាក់ពីសកម្មភាពក្នុងឆ្នាំថ្មីចាប់ពីថ្ងៃទី១ខែមករាដល់ថ្ងៃត្រួតពិនិត្យ(30$)<br>**(100$ + 30$ = 130$)**<br>-បើផលបូកចំនួនសាច់ប្រាក់ដែលនៅសល់ពីឆ្នាំមុន និងចំនួនសមតុល្យសាច់ប្រាក់ពីសកម្មភាពក្នុងឆ្នាំថ្មីចាប់ពីថ្ងៃទី១ខែមករាដល់ថ្ងៃត្រួតពិនិត្យមានចំនួនស្មើនឹងសាច់ប្រាក់នៅដៃក្នុងថ្ងៃត្រួតពិនិត្យ គឺត្រឹមត្រូវ | | | |
| ២ | តើមានសាច់ប្រាក់មួយចំនួនតូចក្នុងទូដែកឬទេ? | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញសាច់ប្រាក់ក្នុងទូដែក | | | |
| ៣ | តើសាច់ប្រាក់មួយចំនួនធំដែលទទួលបានពីការដាក់បញ្ញើសន្សំពីសមាជិកដាក់ក្នុងធនាគារឬទេ? | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញសៀវភៅគណនីផ្ញើធនាគារនិងពិនិត្យចំនួន | | | |

| **របាយការណ៍បែងចែកប្រាក់ចំណេញ** | | | | | |
|---|---|---|---|---|---|
| ១ | តើសហគមន៍កសិកម្មមានដកមូលនិធិបម្រុង ២០%ពីប្រាក់ចំណេញសរុបមិនទាន់បែងចែករៀងរាល់ឆ្នាំដែរឬទេ?* | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញតារាងប្រាក់ចំណេញមិនទាន់បែងចែកនិងតារាងតុល្យការដើម្បីពិនិត្យមើល | | | |
| ២ | តើសហគមន៍កសិកម្មមានដកមូលនិធិបណ្តុះបណ្តាល៣%ពីប្រាក់ចំណេញសរុបមិនទាន់បែងចែករៀងរាល់ឆ្នាំដែរឬទេ? | ពិនិត្យតារាងប្រាក់ចំណេញមិនទាន់បែងចែកនិងតារាងតុល្យការ | | | |
| ៣ | តើប្រាក់ភាគលាភដែលបានផ្តល់ដល់សមាជិកតិចជាង១៥% នៃតម្លៃភាគហ៊ុន? ** | ពិនិត្យតារាងប្រាក់ចំណេញមិនទាន់បែងចែកនិងតារាងតុល្យការ<br>ឧ. ប្រសិនបើតម្លៃភាគហ៊ុនស្មើ ១០០០០៛ នោះប្រាក់ភាគលាភ១៥% នៃតម្លៃភាគហ៊ុនត្រូវស្មើ ១០០០០៛x១៥ ÷ ១០០ = ១៥០០៛ | | | |

| | | | | | |
|---|---|---|---|---|---|
| ៤ | តើសហគមន៍កសិកម្ម មានដកមូលនិធិស្ម័គ្រចិត្តសម្រាប់ទិញទ្រព្យសកម្មរយៈពេលវែង ដើម្បីអភិវឌ្ឍមុខរបរ ឬក្នុងគោលបំណងផ្សេងរបស់សហគមន៍កសិកម្មដែរឬទេ? | ពិនិត្យតារាងប្រាក់ចំណេញមិនទាន់បែងចែកនិងតារាងតុល្យការ | | | |
| ៥ | តើសហគមន៍កសិកម្មបានផ្តល់មូលនិធិលើកទឹកចិត្តសម្រាប់សមាជិកដែលចូលរួមធ្វើជំនួញជាមួយសហគមន៍កសិកម្មដែរឬទេ? | ពិនិត្យរបាយការណ៍បែងចែកប្រាក់ចំណេញ | | | |
| ៦ | តើសហគមន៍កសិកម្ម បានដកប្រាក់ចំណេញរក្សាទុកសម្រាប់បង្កើនទុនដែរឬទេ? | សួរប្រធានក្រុមប្រឹក្សាភិបាលនិងពិនិត្យរបាយការណ៍បែងចែកប្រាក់ចំណេញ | | | |

<u>**ចំណាំ:**</u>

* យោងតាមច្បាប់ស្តីពីសហគមន៍កសិកម្ម មូលនិធិបម្រុងរបស់សហគមន៍កសិកម្មត្រូវតែបង្កើត ដោយត្រូវដកយ៉ាងហោច ២០%ពីប្រាក់ចំណេញសរុបរហូតដល់មូលនិធិបម្រុងនោះមានចំនួន៥ដងនៃប្រាក់ភាគហ៊ុនសរុប។ មូលននិធិនេះមិនត្រូវដកចែកដល់សមាជិកទេ បើមិនដូច្នេះទេ មុខជាប្រឆាំងនឹងច្បាប់។

** ក្នុងច្បាប់សហគមន៍កសិកម្ម ប្រាក់ភាគលាភអាចត្រូវបានផ្តល់ជូនសមាជិកសមាមាត្រទៅតាមភាគហ៊ុនរបស់ពួកគេ ប្រសិនបើសហគមន៍មានប្រាក់ចំណេញប្រចាំឆ្នាំ។ ក្នុងគោលការណ៍សម្ព័ន្ធសហករណ៍អន្តរជាតិ  ប្រាក់ភាគលាភត្រូវតែកំណត់ប្រសិនបើមានប្រាក់ចំណេញ ដូចនៅក្នុងប្រទេសជប៉ុនរដ្ឋាភិបាលបានកំណត់បទបញ្ញានិងការកំណត់ប្រាក់ភាគលាភតិចជាង ៧% និងប្រទេសថៃ ត្រូវបានផ្តល់ជូនសមាជិកត្រឹមតិចជាង១០%នៃតម្លៃភាគហ៊ុនតែប៉ុណ្ណោះ ។ ដូច្នេះសម្រាប់ប្រទេសកម្ពុជា ប្រាក់ភាគលាភគួរផ្តល់ដល់សមាជិក ក្នុងចំនួនតិចជាងឬស្មើ ១៥% នៃតម្លៃភាគហ៊ុនប៉ុណ្ណោះ ក្នុងគោលបំណងដើម្បីបង្កើន ឬបង្កើតឱ្យមានមូលនិធិស្ម័គ្រចិត្ត និងរក្សាទុកសម្រាប់ពង្រីកមុខរបររបស់សហគមន៍កសិកម្ម។

| ***ប្រាក់ផ្ញើធនាគារ*** | | | | | |
|---|---|---|---|---|---|
| ១ | តើសហគមន៍កសិកម្មមានបើកគណនីផ្ញើប្រាក់នៅធនាគារឬទេ? | សុំប្រធានក្រុមប្រឹក្សាភិបាលឱ្យបង្ហាញសៀវភៅគណនីធនាគារ | | | |
| ២ | តើចំនួនប្រាក់ផ្ញើធនាគារដូចគ្នានឹងគណនីប្រាក់ផ្ញើធនាគារក្នុងតារាងតុល្យការឬទេ? | ពិនិត្យចំនួនប្រាក់សន្សំរបស់សហគមន៍ក្នុងសៀវភៅគណនីផ្ញើធនាគារ (របាយការណ៍ធនាគារ)នៅថ្ងៃទី៣១ ខែធ្នូ ហើយផ្ទៀងផ្ទាត់ជាមួយតារាងតុល្យការ | | | |
| ៣ | តើប្រតិបត្តិការសាច់ប្រាក់ចម្បងៗ ត្រូវបានដំណើរការតាមរយៈគណនីធនាគារនេះដែរឬទេ? | -ពិនិត្យមើលប្រតិបត្តិការទីផ្សារសំខាន់ៗដែលមានសកម្មភាពតាមរយៈគណនីធនាគារនេះដែរឬទេ<br>-ពិនិត្យមើលយើងបង់ថ្លៃជីតាមរយៈគណនីធនាគារនេះដែរឬទេ | | | |

## ២.៣ ការត្រួតពិនិត្យ ការអនុវត្តលើមុខរបរ

### ២.៣.១- ត្រួតពិនិត្យលើមុខរបរឥណទាន

| ល.រ | ត្រួតពិនិត្យមើល | របៀបត្រួតពិនិត្យ | មាន | មិនមាន | កំណត់ចំណាំ |
|---|---|---|---|---|---|
| ***ប្រាក់ឱ្យគេខ្ចី(សមាជិកនិងមិនមែនសមាជិក)*** | | | | | |
| ១ | តើសហគមន៍កសិកម្មមានបទបញ្ជាផ្ទៃក្នុងសម្រាប់មុខរបរឥណទានសហគមន៍កសិកម្មដែរឬទេ? | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញបទបញ្ជាផ្ទៃក្នុងសម្រាប់មុខរបរឥណទានសហគមន៍កសិកម្មដែរឬទេ | | | |
| ២ | តើសហគមន៍កសិកម្មមានឯកសារផ្សេងៗ ដូចជា កិច្ចសន្យាខ្ចីប្រាក់ សៀវភៅគណនីប្រាក់ឱ្យខ្ចីរបស់សហគមន៍ សៀវភៅតាមដានប្រាក់សមាជិកខ្ចីម្នាក់ៗ ។ល។ ដែលទាក់ទងនឹងមុខរបរឥណទានសហគមន៍កសិកម្មដែរឬទេ? | សុំឱ្យប្រធានក្រុមប្រឹក្សាភិបាលបង្ហាញឯកសារ ផ្សេងៗ ដូចជា កិច្ចសន្យាខ្ចីប្រាក់ សៀវភៅគណនីប្រាក់ឱ្យខ្ចីរបស់សហគមន៍ សៀវភៅតាមដានប្រាក់ឱ្យសមាជិកឬមិនមែនសមាជិកខ្ចី ។ល។ | | | |
| ៣ | តើការផ្តល់ប្រាក់ឱ្យគេខ្ចីមានអនុវត្តតាមបទបញ្ជាផ្ទៃក្នុងសម្រាប់មុខរបរឥណទានសហគមន៍កសិកម្មដែរឬទេ? | ពិនិត្យមើលឯកសារ ផ្សេងៗ ដូចជា កិច្ចសន្យាខ្ចីប្រាក់ សៀវភៅគណនីប្រាក់ឱ្យខ្ចីរបស់សហគមន៍ សៀវភៅតាមដានប្រាក់សមាជិកខ្ចី ។ល។ និង បទបញ្ជាផ្ទៃក្នុងសម្រាប់មុខរបរឥណទានសហគមន៍កសិកម្ម | | | |
| ៤ | តើមានសមាជិកសហគមន៍កសិកម្មសងប្រាក់ដែលបានឱ្យខ្ចី យឺតជាងការកំណត់ដែរឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវការងារឥណទានបង្ហាញ សៀវភៅតាមដានប្រាក់ឱ្យសមាជិកឬមិនមែនសមាជិកខ្ចី ឬកិច្ចសន្យាខ្ចីប្រាក់ ដើម្បីពិនិត្យកាលបរិច្ឆេទខ្ចី | | | |
| ៥ | បើមានការសងយឺតជាងការកំណត់ តើក្រុមប្រឹក្សាភិបាលមានវិធានការយ៉ាងម៉េច ដោយយោងលើបទបញ្ជាផ្ទៃក្នុងសម្រាប់មុខរបរឥណទានសហគមន៍កសិកម្ម? | សួរទៅក្រុមប្រឹក្សាភិបាល និងពិនិត្យមើលវិធានការនោះ | | | |
| ៦ | តើសហគមន៍កសិកម្មមានបញ្ជីវត្ថុបញ្ចាំដែរឬទេ? | សុំឱ្យក្រុមប្រឹក្សាភិបាលបង្ហាញបញ្ជីវត្ថុបញ្ចាំ | | | |

| | | | | | |
|---|---|---|---|---|---|
| ៧ | តើតម្លៃវត្ថុបញ្ចាំនៅក្នុងបញ្ជីវត្ថុបញ្ចាំស្មើនឹងចំនួនដែលបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងមុខរបរឥណទានសហគមន៍កសិកម្មដែរឬទេ? | ផ្ទៀងផ្ទាត់តម្លៃវត្ថុបញ្ចាំដែលគណនាក្នុងបញ្ជីវត្ថុបញ្ចាំដែលបានគណនាក្នុងបទបញ្ជាផ្ទៃក្នុងមុខរបរឥណទានសហគមន៍កសិកម្ម ជាមួយចំនួនប្រាក់ដែលបានឱ្យគេខ្ចី។ | | | |
| ៨ | តើតម្លៃវត្ថុបញ្ចាំពិតប្រាកដស្មើនឹងតម្លៃក្នុងបញ្ជីវត្ថុបញ្ចាំដែរឬទេ? | ពិនិត្យបទបញ្ជាផ្ទៃក្នុងមុខរបរឥណទានសហគមន៍កសិកម្ម និងតម្លៃវត្ថុបញ្ចាំ និងតម្លៃពិតប្រាកដនៃវត្ថុបញ្ចាំ<br>-បើជាដី ដោយសាកសួរអ្នកជិតខាងដីនោះ និងប្រធានភូមិ/ឃុំ សួរនាយកដ្ឋានពន្ធដារ ឬនាយកដ្ឋានសុរិយោដី<br>-បើជាបរិក្ខារសួរអ្នកលក់ | | | |
| ៩ | តើការផ្តល់ប្រាក់កម្ចីដល់សមាជិកច្រើនជាងអ្នកមិនមែនសមាជិកឬទេ? | សាកសួរសមាជិក២ឬ៣នាក់តើ ប្រាក់ឱ្យសមាជិកខ្ចីបំពេញតម្រូវការពួកគាត់ដែរឬទេ | | | |

| ***ប្រាក់បញ្ញើសន្សំរបស់សមាជិកនិងមិនមែនសមាជិក*** | | | | | |
|---|---|---|---|---|---|
| ១ | តើសហគមន៍កសិកម្មមានផ្តល់សៀវភៅប្រាក់បញ្ញើសន្សំដល់សមាជិកម្នាក់ៗដែលដាក់ប្រាក់សន្សំនិងបំពេញចំនួនដែលសន្សំដែរឬទេ? | សួរក្រុមប្រឹក្សាភិបាល និងសមាជិក ១-២ នាក់ | | | |
| ២ | បើមាន តើចំនួនទឹកប្រាក់សន្សំក្នុងសៀវភៅប្រាក់បញ្ញើសន្សំរបស់សហគមន៍កសិកម្មដូចសៀវភៅបញ្ញើសន្សំរបស់សមាជិកម្នាក់ៗដែរឬទេ? | សួរសមាជិកដើម្បីរកសៀវភៅសន្សំរបស់សមាជិក ៣ - ៤នាក់មកពិនិត្យផ្ទៀងផ្ទាត់ជាមួយសៀវភៅប្រាក់បញ្ញើសន្សំរបស់សហគមន៍ | | | |
| ៣ | តើសហគមន៍កសិកម្មមានទុកប្រាក់នៅក្នុងធនាគារដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងមុខរបរឥណទានសហគមន៍កសិកម្ម សម្រាប់ត្រៀមពេលសមាជិកដកប្រាក់បញ្ញើសន្សំវិញដែរឬទេ? ឧ. ធនាគារ អេស៊ីលីដា | សួរក្រុមប្រឹក្សាភិបាលឱ្យបង្ហាញសៀវភៅធនាគារ ដែលសហគមន៍ដាក់ប្រាក់ និងគណនារកចំនួន(%)ដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងដែលទុកប្រាក់នេះសម្រាប់សមាជិកដែលចង់ដកប្រាក់បន្ទាន់ ថាតើចំនួននេះដូចគ្នានឹងចំនួនប្រាក់ក្នុងសៀវភៅធនាគាររបស់AC ដែរឬទេ<br>*ឧ.សហគមន៍យកដប្រាក់ដែលសាមជិកដាក់សន្សំ១០%នៅធនាគារអេស៊ីលីដាសម្រាប់ពេលសមាជិកត្រូវការដកបន្ទាន់* | | | |

| | | | | | |
|---|---|---|---|---|---|
| ៤ | តើសហគមន៍កសិកម្មគណនាការប្រាក់សន្សំបានត្រឹមត្រូវនិងផ្តល់ជូនសមាជិកដែរឬទេ? | សួរក្រុមប្រឹក្សាភិបាលឱ្យបង្ហាញសៀវភៅសន្សំរបស់សមាជិកម្នាក់ៗ និងសួរសមាជិក ២ -៣នាក់ អំពីការប្រាក់ដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងមុខរបរឥណទានសហគមន៍កសិកម្ម | | | |

## ២.៣.២-ត្រួតពិនិត្យលើមុខរបរផ្គត់ផ្គង់ (ការទិញទំនិញមកលក់ឱ្យសមាជិក និងអ្នកខាងក្រៅ)

| | ត្រួតពិនិត្យមើល | របៀបត្រួតពិនិត្យ | មាន | មិនមាន | កំណត់ចំណាំ |
|---|---|---|---|---|---|
| ***តម្លៃ ប្រាក់ចំណេញ និងបញ្ជីសារពើភ័ណ្ឌ*** | | | | | |
| ១ | តើសហគមន៍កសិកម្មអាចផ្គត់ផ្គង់ធាតុចូលកសិកម្មនិងសម្ភារៈផ្សេងៗដល់សមាជិកក្នុងតម្លៃដូចគ្នាឬទាបជាងតម្លៃនៅហាងលក់រាយឬទីផ្សារដែរឬទេ? | សាកសួរប្រធាននិងពិនិត្យតម្លៃនៅក្នុងសៀវភៅផ្គត់ផ្គង់និងហាងលក់រាយមួយចំនួន | | | |
| ២ | តើមុខរបរផ្គត់ផ្គង់របស់សហគមន៍កសិកម្មអាចទទួលបានប្រាក់ចំណេញដែរឬទេ? | ស្នើឱ្យក្រុមប្រឹក្សាភិបាលបង្ហាញរបាយការណ៍ចំណេញ ខាត និងពិនិត្យត្រង់មុខរបរផ្គត់ផ្គង់ | | | |
| ៣ | តើបរិមាណផ្គត់ផ្គង់ដូចគ្នាទៅនឹងចំនួនកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌដែរឬទេ? | ស្នើឱ្យក្រុមប្រឹក្សាភិបាលបង្ហាញពីសៀវភៅផ្គត់ផ្គង់និងបញ្ជីសារពើភ័ណ្ឌនិងត្រួតពិនិត្យមើល (ស្តុកចេញទៅសមាជិក) | | | |
| ៤ | តើចំនួនស្តុកសម្រាប់ផ្គត់ផ្គង់ ដែលនៅសល់សរុប ដូចគ្នាទៅនឹងទំនិញជាក់ស្តែងដែលនៅសល់ក្នុងស្តុកដែរឬទេ? | ពិនិត្យបញ្ជីសារពើភ័ណ្ឌនិងស្តុកជាក់ស្តែងដែលនៅសល់ ។ វាត្រូវតែមានចំនួនដូចគ្នា។ | | | |

## ២.៣.៣-ត្រួតពិនិត្យលើមុខរបរទីផ្សារ (ការទិញកសិផលពីសមាជិកលក់ទៅទីផ្សារ)

| | ត្រួតពិនិត្យមើល | របៀបត្រួតពិនិត្យ | មាន | មិនមាន | កំណត់ចំណាំ |
|---|---|---|---|---|---|
| ***តម្លៃ ប្រាក់ចំណេញ និងបញ្ជីសារពើភ័ណ្ឌ*** | | | | | |
| ១ | តើសហគមន៍កសិកម្មអាចទិញផលិតផលកសិកម្ម (ស្រូវ អង្ករ។ល។) ពីសមាជិកនៅក្នុងតម្លៃដូចគ្នាឬខ្ពស់ជាងតម្លៃទីផ្សារដែរឬទេ? | សាកសួរប្រធាននិងពិនិត្យជាមួយសមាជិកពីរ បីនាក់និងតម្លៃទីផ្សារ | | | |
| ២ | តើមុខរបរទីផ្សាររបស់សហគមន៍កសិកម្ម អាចទទួលបានប្រាក់ចំណេញដែរឬទេ? | ស្នើឱ្យក្រុមប្រឹក្សាភិបាលបង្ហាញរបាយការណ៍ចំណេញ ខាត និងពិនិត្យត្រង់មុខរបរទីផ្សារ | | | |

| | | | | | |
|---|---|---|---|---|---|
| ៣ | តើបរិមាណលក់ដូចគ្នាទៅនឹងចំនួនកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌដែរឬទេ? | ស្នើឱ្យក្រុមប្រឹក្សាភិបាលបង្ហាញពីសៀវភៅលក់និងបញ្ជីសារពើភ័ណ្ឌនិងត្រួតពិនិត្យមើល (ស្តុកចេញ ទៅទីផ្សារ) | | | |
| ៤ | តើចំនួនស្តុកសម្រាប់លក់ទៅទីផ្សារដែលនៅសល់សរុប ដូចគ្នាទៅនឹងទំនិញជាក់ស្តែងដែលនៅសល់ក្នុងស្តុកដែរឬទេ? | ពិនិត្យបញ្ជីសារពើភ័ណ្ឌនិងស្តុកជាក់ស្តែងដែលនៅសល់ ។ វាត្រូវតែមានចំនួនដូចគ្នា | | | |

## ជំហានទី ៣. សភាពការណ៍ដែលបានកត់សម្គាល់ពីការត្រួតពិនិត្យ

យោងតាមច្បាប់និងបទបញ្ជារបស់សហគមន៍កសិកម្ម បន្ទាប់ពីគណកម្មាធិការត្រួតពិនិត្យដំណាច់ឆ្នាំលើរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលរួច ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ត្រូវជូនពត៌មានស្តីពីសភាពការណ៍ដែលបានកត់សំគាល់ទៅក្រុមប្រឹក្សាភិបាល នូវការរកឃើញឯកសារដែលត្រឹមត្រូវ និងមិនត្រឹមត្រូវនៅកំឡុងពេលត្រួតពិនិត្យ បន្ទាប់មកធ្វើការណែនាំដល់ក្រុមប្រឹក្សាភិបាលកែលម្អនូវឯកសារឱ្យបានត្រឹមត្រូវ និងត្រូវរៀបចំរបាយការណ៍ត្រួតពិនិត្យដើម្បីបញ្ជាក់ ហើយភ្ជាប់ជាមួយរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដើម្បីដាក់ជូនមហាសន្និបាត។

ក្នុងករណីដែលត្រួតពិនិត្យទៅឃើញថាមានកំហុស គណៈកម្មាធិការត្រួតពិនិត្យស្នើឱ្យក្រុមប្រឹក្សាភិបាលធ្វើការកែលម្អការងារទាំងនោះ។ ក្រុមប្រឹក្សាភិបាលត្រូវកែលម្អការងារទាំងនោះនិងបញ្ជូនមកវិញម្តងទៀតជាបន្ទាន់ ឬឱ្យបានឆាប់តាមតែអាចធ្វើទៅបាន និងឱ្យបានមុនពេលធ្វើមហាសន្និបាតប្រចាំឆ្នាំ ។

ខាងក្រោមនេះជារបាយការណ៍ត្រួតពិនិត្យរបស់គណកម្មាធិការត្រួតពិនិត្យដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្មដើម្បីដាក់ជូនមហាសន្និបាតៈ

**ក្នុងករណីគ្មានកំហុស**

## របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការត្រួតពិនិត្យ

ថ្ងៃទី……… ខែ………. ឆ្នាំ201….

នេះជារបាយការណ៍របស់គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម…………………។

នៅថ្ងៃទី ........... ខែ.......... ឆ្នាំ201........ គណៈកម្មាធិការត្រួតពិនិត្យ បានត្រួតពិនិត្យ បញ្ជីគណនេយ្យ បញ្ជីទ្រព្យសម្បត្តិសហគមន៍កសិកម្ម ..................................................... និងឯកសារសំខាន់ៗរបស់សហគមន៍កសិកម្ម ដោយគោរពតាមច្បាប់ស្តីពីសហគមន៍កសិកម្មក្នុង មាត្រា50 និងមាត្រា52 ដែលតម្រូវឱ្យគណៈកម្មាធិការត្រួតពិនិត្យប្រើសិទ្ធនិងកាតព្វកិច្ចត្រួតពិនិត្យបញ្ជីគណនេយ្យ របស់សហគមន៍ ។

គណៈកម្មាធិការត្រួតពិនិត្យ បានរកឃើញថា គ្រប់ចំណុចដែលបានត្រួតពិនិត្យ មានការរៀបចំបានត្រឹមត្រូវ ។

**គណៈកម្មាធិការត្រួតពិនិត្យ**
**ហត្ថលេខា**

**ប្រធានគណៈកម្មាធិការត្រួតពិនិត្យ**

ឈ្មោះ៖...................................................
កាលបរិច្ឆេទ....................................................

**ករណីមានកំហុស**

នេះជារបាយការណ៍របស់គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម................................។

នៅថ្ងៃទី......... ខែ........ ឆ្នាំ........ គណៈកម្មាធិការត្រួតពិនិត្យ បានត្រួតពិនិត្យ បញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌ តារាងតុល្យការ របាយការណ៍លទ្ធផល(ចំណេញ ខាត) និងឯកសារសំខាន់ៗរបស់សហគមន៍កសិកម្ម ដោយគោរពតាមច្បាប់ស្តីពីសហគមន៍កសិកម្មក្នុង មាត្រា50 និងមាត្រា52ដែលតម្រូវឱ្យគណៈកម្មាធិការត្រួតពិនិត្យប្រើសិទ្ធនិងកាតព្វកិច្ចត្រួតពិនិត្យបញ្ជីគណនេយ្យ របស់សហគមន៍កសិកម្ម ។

គណៈកម្មាធិការត្រួតពិនិត្យ បានរកឃើញថា មានការក្លែងបន្លំឯកសារដូចបានរៀបរាប់ខាងក្រោម នៅក្នុងបញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌ តារាងតុល្យការ របាយការណ៍លទ្ធផល(ចំណេញ ខាត) និង ឯកសារសំខាន់ៗរបស់សហគមន៍កសិកម្ម។

ឧទាហរណ៍៖ ក្នុងករណីដែលត្រួតពិនិត្យទៅឃើញមានកំហុសណាមួយដូចខាងក្រោម៖

- សាច់ប្រាក់ក្នុងដៃមិនគ្រប់តាមបញ្ជីសមតុល្យដែលនៅសល់
- ការចំណាយគ្មានវិក័យបត្រត្រឹមត្រូវ និងខុសនីតិវិធីចំណាយ
- ការចំណាយគ្មានការឯកភាពពីថ្នាក់ដឹកនាំ
- ការគណនាចំណូលចំណាយមិនត្រឹមត្រូវ
- ជាចំណាយផ្ទាល់ខ្លួន មិនមែនជាចំណាយរបស់សហគមន៍កសិកម្ម
- ការពិនិត្យរាប់ចំនួនសម្ភារៈរបស់សហគមន៍កសិកម្មមានបាត់បង់
- មិនមានបញ្ជីតាមដានសមាជិកឬមិនមែនសមាជិកខ្ចីប្រាក់ត្រឹមត្រូវ
- គ្មានបញ្ជីគ្រប់គ្រងផលិតផលរបស់សមាជិកត្រឹមត្រូវ
- រៀបចំកត់ត្រាក្នុងប្រព័ន្ធគណនេយ្យមិនបានត្រឹមត្រូវ
- ………………………………………………………

គណៈកម្មាធិការត្រួតពិនិត្យ នឹងមានគោលការណ៍មួយយោងតាមច្បាប់ខាងលើ សម្រេចឱ្យក្រុមប្រឹក្សាភិបាលត្រួត ពិនិត្យឡើងវិញនិងកែតម្រូវនូវអ្វីដែលមិនមានភាពប្រក្រតីនិងប្រព្រឹត្តខុសខាងលើ។

**គណៈកម្មាធិការត្រួតពិនិត្យ**

**ហត្ថលេខា**

**ប្រធានគណៈកម្មាធិការត្រួតពិនិត្យៈ**

ឈ្មោះ៖..................................................

កាលបរិច្ឆេទ..................................................

## ជំហានទី ៤. ការរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការត្រួតពិនិត្យ

ជំហាននេះគឺការបញ្ចូលគ្នានូវសកម្មភាពការងារពេញមួយឆ្នាំ និងការត្រួតពិនិត្យដំណាច់ឆ្នាំរបស់គណៈកម្មាធិការត្រួតពិនិត្យ។ ក្រោយពីផ្ដល់នូវព័ត៌មានអ្វីដែលបានការកត់សម្គាល់ដល់ក្រុមប្រឹក្សាភិបាល គណកម្មាធិការត្រួតពិនិត្យត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដើម្បីប្រគល់ជូនមហាសន្និបាត។

ប្រសិនបើគណៈកម្មាធិការត្រួតពិនិត្យ ប្រជុំតាមដានរៀងរាល់ខែចាប់ពីខែមករា ដល់ខែធ្នូ ពួកគេគ្រាន់តែសរសេរថ្ងៃខែដែលប្រជុំតាមដាននោះ និងបើសិនពួកគេ បានរកឃើញកំហុស ពួកគេអាចរៀបរាប់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់គាត់ និងរាយការណ៍ក្នុងមហាសន្និបាត។

ឧទាហរណ៍៖ បានប្រជុំតាមដាននៅខែ ខែកុម្ភៈ ខែមេសា ខែឧសភា ខែកញ្ញា ខែវិច្ឆិកា និង ត្រួតពិនិត្យសម្រាប់ដំណាច់ឆ្នាំ គឺៈ

ខាងក្រោមជាឧទាហរណ៍របាយការណ៍ប្រចាំឆ្នាំសង្ខេបរបស់គណៈកម្មាធិការត្រួតពិនិត្យៈ

| កាលបរិច្ឆេទ | អ្នកចូលរួម | របៀបវារៈ | កំណត់សំគាល់ |
|---|---|---|---|
| ២-៣ កុម្ភៈ ២០១៥ | ៨ | ការបង់ប្រាក់ភាគហ៊ុនរបស់សមាជិក សកម្មភាពជំនួញរបស់ក្រុមប្រក្សាភិបាល ការអនុវត្តប្រភេទមុខជំនួញដែលបានសម្រេចដោយមហាសន្និបាត | មិនមានបញ្ហាអ្វី |
| ៥-៦ មេសា ២០១៥ | ៧ | ការផ្ដល់ប្រាក់ឱ្យគេខ្ចី និងឯកសារពាក់ព័ន្ធដូចជា កិច្ចសន្យាខ្ចីប្រាក់ ការចុះក្នុងសៀវភៅប្រាក់ឱ្យខ្ចីរបស់សមាជិក វិក័យបត្រ័ចំណាយ សាច់ប្រាក់ចូល និងឯកសារភស្តុតាងផ្សេងៗពាក់ព័ន្ធមុខជំនួញ | មិនមានបញ្ហាអ្វី |
| ០២-០៣ ឧសភា ២០១៥ | ៨ | ការផ្ដល់ប្រាក់ឱ្យគេខ្ចី និងឯកសារពាក់ព័ន្ធដូចជា កិច្ចសន្យាខ្ចីប្រាក់ ការចុះក្នុងសៀវភៅប្រាក់ឱ្យខ្ចីរបស់សមាជិក វិក័យបត្រ័សាច់ប្រាក់ចេញ ប្រតិបត្តិការចំណាយ សាច់ប្រាក់ចូល សមាជិកដាក់ប្រាក់សន្សំ លក់ និងទិញជំពាក់ និងឯកសារភស្តុតាងផ្សេងៗពាក់ព័ន្ធមុខជំនួញ | បានរកឃើញកំហុសថាការប្រាក់នៃប្រាក់កម្ចីគណនាខុស |
| ០២-០៣ កញ្ញា ២០១៥ | ៦ | ការផ្ដល់ប្រាក់ឱ្យគេខ្ចី និងឯកសារពាក់ព័ន្ធដូចជា កិច្ចសន្យាខ្ចីប្រាក់ ការចុះក្នុងសៀវភៅប្រាក់ឱ្យខ្ចីរបស់សមាជិក វិក័យបត្រ័សាច់ប្រាក់ចេញ ប្រតិបត្តិការចំណាយ សាច់ប្រាក់ចូល សមាជិកដាក់ប្រាក់សន្សំ លក់ និងទិញជំពាក់ និងឯកសារភស្តុតាងផ្សេងៗពាក់ព័ន្ធមុខជំនួញ | មិនមានបញ្ហាអ្វី |

| | | | |
|---|---|---|---|
| ០៣-០៤ វិច្ឆិកា ២០១៥ | ៨ | ការផ្តល់ប្រាក់ឱ្យគេខ្ចី និងឯកសារពាក់ព័ន្ធដូចជា កិច្ចសន្យាខ្ចីប្រាក់ ការចុះក្នុងសៀវភៅប្រាក់ឱ្យខ្ចីរបស់សមាជិក វិក័យបត្រ័សាច់ប្រាក់ចេញ ប្រតិបត្តិការចំណាយ សាច់ប្រាក់ចូល សមាជិកដាក់ប្រាក់សន្សំ លក់ និងទិញ ជំពាក់ និងឯកសារភស្តុតាងផ្សេងៗពាក់ព័ន្ធមុខជំនួញ | មិនមានបញ្ហាអ្វី |
| ១៥-១៦ កុម្ភៈ ២០១៦ | ៨ | តារាងតុល្យការ របាយការណ៍ចំណេញឬខាតទ្រព្យសម្បត្តិរបស់សហគមន៍ សាច់ប្រាក់ក្នុងដៃ និងឯកសារ ភស្តុតាងសផ្សេងៗ ពាក់ព័ន្ធមុខជំនួញ | បាត់វិក័យប័ត្រ ចំណាយ១ សន្លឹក |

## ជំហានទី ៥. ការរាយការណ៍ជូនមហាសន្និបាត

ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ត្រូវរាយការណ៍នូវរបាយការណ៍ចំណុចសំខាន់ៗ ដែលបានសរុបក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនជូនមហាសន្និបាត ។

Guideline on Agricultural Cooperative Monitoring for Supervisory Monitoring

Printed in February 2016

Published by Department of Agricultural Cooperative Promotion of GDA (MAFF)

The Project for Establishing Business Oriented Agricultural Cooperative Models (BPAC)

Address: #54B/49F.St395-656,Sangkat Toeuk Laak 3 Khan Tuol Kok, Phnom penh ,Cambodia,

Phone: (023) 883 427, Fax : 023) 883 427

© The Project for Establishing Business-Oriented Agricultural Cooperative Models

Supported by Japan International Cooperation Agency (JICA)